THE UNIVERSITY OF AUCKLAND Te Whare Wānanga o Tāmaki Makaurau NEW ZEALAND · THE UNIVERSITY OF WESTERN AUSTRALIA · THE UNIVERSITY OF SYDNEY · USP THE UNIVERSITY OF THE SOUTH PACIFIC · Royal University of Phnom Penh

# ការបន្សាំទៅនឹងបំរែបំរួលអាកាសធាតុក្នុងការស្តារឡើងវិញបន្ទាប់ពីរង គ្រោះមហន្តរាយ៖ សេចក្តីសង្ខេបសម្រាប់គោលនយោបាយសង្ខេបទី៣

## យុទ្ធសាស្ត្រប្រកបមុខរបរចញ្ចឹមជីវិតតាមរដូវកាល និងការបន្សាំនឹងបរិស្ថានមិនជាក់លាក់ក្នុងពេលអនាគត៖ លទ្ធផលពី វិធីសាស្ត្រចូលរួមក្នុងស្រុកព្រែកប្រសព្វ ខេត្តក្រចេះនៃព្រះរាជាណាចក្រកម្ពុជា

---

សេចក្តីសង្ខេបគោលនយោបាយនេះ រៀបរាប់ពីការឆ្លុះបញ្ចាំងទៅលើភាពធន់ និងសមត្ថភាពបន្សាំរបស់សហគមន៍រងការប៉ះពាល់ដោយទឹកជំនន់នៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះនៃព្រះរាជាណាចក្រកម្ពុជា។ វាបានបង្ហាញពីយុទ្ធសាស្ត្រផ្សេងៗ ដែលបានប្រើប្រាស់ដោយសហគមន៍ ជាពិសេសស្ត្រី ដើម្បីសម្រប ជីវភាពរស់នៅរបស់ពួកគេធន់ទៅនឹងព្រឹត្តិការណ៍ធំៗ និងការប្រែប្រួលបរិស្ថានទៅតាមរដូវកាល។ សេចក្តីសង្ខេប រៀបរាប់ពីលទ្ធផលបញ្ចូលគ្នា រវៀងលទ្ធផលទទួលបានពីសិក្ខាសាលាចំនួន ៩ ដែលបានធ្វើក្នុងភូមិចំនួន ៤ នៃឃុំចំនួន ២ ដោយប្រើប្រាស់វិធីសាស្ត្រក្រុមពិភាក្សាជាមួយស្ត្រី និងបុរស ដើម្បីបង្កើតប្រតិទិន្នរដូវកាល និងកំណត់ហេតុសកម្មភាពប្រចាំថ្ងៃ។ ចំណេះដឹងសហគមន៍ គឺមានតម្លៃដូចនឹងចំណេះដឹងខាងវិទ្យាសាស្ត្រដែរ និងរួមបញ្ចូលភាពលំអិតនៃចំណេះដឹងកសិកម្ម និងការប្រែប្រួលអាកាសធាតុ ដែលឧបករណ៍វិទ្យាសាស្ត្រ មានដូចជាគំរូនៃផលិតភាពដំណាំកសិកម្ម ការបំពេញទឹកទន្លេ និងទឹកភ្លៀងដែលមិនអាចរក្សាទុកបាន។

## សារជាគន្លឹះ

- កម្ពុជានឹងជួបប្រទះគ្រោះរាំងស្ងួត និងទឹកជំនន់ធំៗ ថតចុះនូវរបបទឹកភ្លៀងក្នុងរដូវវស្សា និងលំហូរទឹកទន្លេមិនអាចប៉ាន់ស្មានដឹង។ ថ្មីៗនេះ តំបន់ជនបទបានជួបប្រទះគ្រោះរាំងស្ងួត (២០១៥-២០១៧) និងទឹកជំនន់ (២០១៣, ២០១៨)។ ប្រើប្រាស់វិធីសាស្ត្រចូលរួម និងក្រុមពិភាក្សាលើបទពិសោធន៍របស់ក្រុមស្ត្រី ដើម្បីជូនដំណឹងដល់អ្នកធ្វើគោលនយោបាយ និងផែនការ ដើម្បីអាចជួយបន្សាំ និងការការបញ្ជ្រាបយេនឌ័រ។
- ការរួមបញ្ចូលគ្នារវៀងវិធីសាស្ត្រក្រុមពិភាក្សាជាមួយក្រុមគោលដៅនៅក្នុងសហគមន៍មូលដ្ឋានការបង្កើតប្រតិទិនតាមរដូវ និងការប្រមូលផ្តុំនៃសកម្មភាពប្រចាំថ្ងៃរបស់អ្នកភូមិពេញមួយឆ្នាំ អាចផ្តល់ការប្រមើលមើលដ៏មានតម្លៃពីការប្រែប្រួលតាមរដូវ និងប្រចាំឆ្នាំ ក្នុងលក្ខខណ្ឌបរិស្ថាន និងការជួបប្រទះជាក់ស្តែងរបស់ស្ត្រី ក្នុងការរៀបចំ និងទប់ទល់ជាមួយព្រឹត្តិការណ៍អាកាសធាតុប្រែប្រួលធំៗ។ ការយល់

Funded by APN ASIA-PACIFIC NETWORK FOR GLOBAL CHANGE RESEARCH

ដឹងពីចំនុចសំខាន់នៃសម្ពាធសម្ពាធអាកាសធាតុ អាចបង្ហាញឲ្យឃើញ នៅពេលការអនុវត្តកសិកម្មបច្ចុប្បន្ន អាចនឹងងាយរងគ្រោះដោយការប្រែប្រួលបរិស្ថាន។

- ឆ្លើយតបទៅនឹងលទ្ធភាពប្រើប្រាស់ទឹក បានជាអតិបរិមា ប្រចាំឆ្នាំ និងភាពមិនទៀងទាត់នៃរដូវកាល និងការកើតឡើងនូវគ្រោះរាំងស្ងួត និងទឹកជំនន់ សហគមន៍បានបង្កើតការឆ្លើយតប និងការបន្សាំមានភាពប្រទាក់ក្រឡា និងសាំញ៉ាំ ដើម្បីការបន្ថយគ្រោះហានិភ័យនៃការបំផ្លាញដំណាំ និងប្រើប្រាស់ភាពផលិតផលចម្រុះ និងយុទ្ធសាស្ត្រដើម្បីថែរក្សាជីវភាពរស់នៅរបស់ពួកគេ។

## បរិបទ

ការប្រកបរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង នៃតំបន់អាងមេគង្គក្រោម គឺផ្សាភ្ជាប់ទៅនឹងទន្លេ តាមរយៈ កសិកម្ម ការនេសាទ វារីអគ្គិសនី និងផ្នែកផ្សេងៗទៀត។ ក្នុងប្រទេសកម្ពុជា ៨៥% នៃដីដែលអាចដំដុះបានគឺដាំស្រូវ ដែលការធ្វើស្រែស្ទើរតែទាំងអស់ពឹងផ្អែកលើទឹកភ្លៀង។ ប៉ុន្មានឆ្នាំថ្មីៗនេះ សន្តិសុខស្បៀងជួបប្រទះបញ្ហានៅតាមសហគមន៍ជនបទជាច្រើន ដោយសារកើនឡើងរដូវកាលមិនទៀងទាត់ និងគ្រោះទឹងជំនន់ និងគ្រោះរាំងស្ងួតយ៉ាងធ្ងន់ធ្ងរ។ កម្ពុជា បានរងផលប៉ះពាល់ដោយគ្រោះរាំងស្ងួតតាំងពីឆ្នាំ ២០១៥ ដល់ ២០១៧ និងជួបប្រទះគ្រោះទឹកជំនន់បំផ្លិចបំផ្លាញក្នុងឆ្នាំ ២០១១ ឆ្នាំ២០១៣ និងឆ្នាំ ២០១៨។ ការប៉ាន់ស្មានបច្ចុប្បន្នសម្រាប់ការប្រែប្រួលអាកាសធាតុ ក្នុងពេលអនាគតបានបង្ហាញពី ភាពងាយរងគ្រោះនៃកសិកម្មស្រូវ ដែលពឹងផ្អែកលើទឹកភ្លៀងនៅតាមដងទន្លេមេគង្គក្រោម ហើយកំណើនឡើងរដូវកាលមិនទៀងទាត់នឹងនៅតែបន្ត។ ការវិភាគវិទ្យាសាស្ត្រ ទំនោទៅរកការព្យាករណ៍ថា ភ្លៀងធ្លាក់ដើមឆ្នាំមានភាពយឺតយ៉ាវ កំណើនឡើងភាពញឹកញាប់ និងទំហំនៃទឹកជំនន់ធំៗតាមដងទន្លេមេគង្គ កើនឡើងសីតុណ្ហភាពមធ្យម និងរយៈពេលរាំងស្ងួតយូរជាងកំឡុងពេលរដូវវស្សា។ ឆ្លើយតបទៅនឹងការគម្រាមកំហែងទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់ឆ្នាំ២០១៤-២០២៣។ បេសកកម្មនៃផែនការនេះគឺដើម្បីបង្កើត ក្របខ័ណ្ឌថ្នាក់ជាតិសម្រាប់ភាគីពាក់ព័ន្ធក្នុងដំណើរការចូលរួម និងប្រើប្រាស់ពីចំណោះសហគមន៍ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រនេះ ថែមទាំងបានបង្ហាញពីសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការប្រែប្រួលអាកាសធាតុ ដូចជាស្ត្រីជនបទ គឺស្ថិតក្នុងចំណោមក្រុមដែលទទួលផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការប្រែប្រួលអាកាសធាតុ។ ការស្រាវជ្រាវនេះ បានបង្ហាញថា តាមរយៈការផ្តោតលើចំនេះដឹងក្នុងមូលដ្ឋាន ការបន្សាំ និងផលប៉ះពាល់ជាក់លាក់លើយេនឌ័រនៃការប្រែប្រួលបរិស្ថាន មានពាក់ព័ន្ធដោយផ្ទាល់សម្រាប់ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជា។

## ការប្រកបរបរចិញ្ចឹមជីវិតតាមរដូវកាល និងយុទ្ធសាស្ត្របន្សាំ

Participatory workshops were conducted in four villages in the Prek Prasop district of Kratie province. The four villages present a cross-section of rural livelihoods along the lower Mekong River, ranging from villages situated at various elevations on the natural levee of the Mekong, to a community on an island. The main focus of the workshops was to develop seasonal livelihood calendars. Figure 1 presents a seasonal calendar compiled from two workshops in one example village, with one workshop primarily informed by women, and the other predominantly by men participants.

សិក្ខាសាលាពិភាក្សាដោយមានការចូលរួម ដែលបានធ្វើក្នុងភូមិចំនួន ៤ ក្នុងស្រុកព្រែកប្រសព្វនៃខេត្តក្រចេះ។ ភូមិទាំងបួន រៀបរាប់ពីភាពចម្រុះវិស័យនៃការប្រកបរបរចិញ្ចឹមជីវិតនៅជនបទតាមដងទន្លេមេគង្គក្រោម ចាប់ពីភូមិ ដែលស្ថិតនៅនូវរយៈកំពស់ខុសៗគ្នាក្នុងភូមិសាស្ត្រធម្មជាតិនៃទន្លេមេគង្គ ទៅដល់សហគមន៍នៅលើកោះមួយ។ គោលបំណងសំខាន់នៃសិក្ខាសាលាទាំងនេះ គឺដើម្បីបង្កើតប្រតិទិនការប្រកបរបរចិញ្ចឹមជីវិតតាមរដូវកាល។ រូបភាពទី១ បានរៀបរាប់ពីប្រតិទិនតាមរដូវកាល បានរួមបញ្ចូលពីសិក្ខាសាលាពីរក្នុងភូមិតែមួយ ដែលសិក្ខាសាលាមួយរៀបរាប់ពីមូលដ្ឋានចូលរួមដោយស្ត្រី និង មួយផ្សេងទៀតចូលរួមយ៉ាងលើសលុបដោយបុរស។




រូបទី១ ឧទាហរណ៍មួយនៃប្រតិទិនរដូវកាលបង្ហាញពីប្រភេទពេលវេលានៃព្រឹត្តិការឧតុនិយមសំខាន់ៗ និងគន្លឹះសកម្មភាពចិញ្ចឹមជីវិត។ អ្នកភូមិបានកំណត់សំគាល់ពេលវេលានៃសកម្មភាពចិញ្ចឹមជីវិតអាចប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ផ្អែកលើគំរូទឹកភ្លៀង និងទឹកជំនន់ផ្សេងៗ។ ប្រតិទិនបានបង្ហាញខាងលើបង្ហាញសកម្មភាពប្រែប្រួលនៃពេលវេលាទាក់ទងទៅនឹងរយៈពេលភ្លៀងយូរ និងរដូវទឹកជំនន់ក្នុងភូមិសិក្សាមួយ។ ឧទាហរណ៍ ប្រសិនបើដើមរដូវភ្លៀងធ្លាក់មិនទាន់បញ្ចប់ កសិករអាចនឹងសម្រេចចិត្តមិនសាបព្រោះស្រូវនៅរដូវវស្សា ឬពួកគេអាចនឹងជ្រើសរើសដាំប្រភេទអង្ករដែលអាចដាំក្នុងខែកក្កដា និងចំណាយពេលតិចដើម្បីបានផល។ មិនបានបង្ហាញដំណាំដែលអាចលូតលាស់ និងប្រើប្រាស់ដោយគ្រួសារពេញមួយឆ្នាំ ដូចជាដូង ចេក និងច្បារដំណាំតាមផ្ទះ។

ទោះជាសកម្មភាពចិញ្ចឹមជីវិតលំអិត មានភាពខុសៗក្នុងចំណោមភូមិទាំងបួន ឧទាហរណ៍បាន បង្ហាញក្នុងរូបទី១ តួរយ៉ាងការចែករំលែកគន្លឹះសំខាន់មួយចំនួនក្នុងទីតាំងសិក្សា។ រដូវច្រូតកាត់ (បាន បង្ហាញដោយពណ៌បៃតងចាស់ក្នុងរូបទី១) សម្រាប់ភាពខុសគ្នានៃសកម្មភាពសេដ្ឋកិច្ចសំខាន់ៗគឺការ ផ្សព្វផ្សាយតាមរយៈប្រតិទិនប្រចាំឆ្នាំ និងការផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ជាឧទាហរណ៍ ស្រូវវស្សាគឺ ពឹងផ្អែកលើទឹកភ្លៀង និងលូតលាស់នៅរយៈកំពស់ខ្ពស់មួយ ដែលអាចកាត់បន្ថយការបំផ្លាញដោយមហន្ត រាយទឹកជំនន់ ខណៈស្រូវប្រាំងគឺលូតលាស់នៅតំបន់រយៈកំពស់ទាបតាមទឹកស្រកចុះ និងអាចបំប៉នដោយ ប្រព័ន្ធស្រូចស្រប។ សារៈសំខាន់នៃដំណាំដើមឈើរួម មានស្វាយចន្ទី និងស្វាយ ដែលស្វាយខុសរដូវទទួល បានប្រាក់ចំនូលខ្ពស់ជាង ដែលមាននៅតាមភូមិមួយចំនួន។

**បទពិសោធន៍យេនឌ័រនៃការប្រែប្រួលរដូវកាល និងព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុធំៗ**

កំឡុងពេលការពិភាក្សាក្រុម ស្ត្រី និងបុរសបានសង្កត់ទៅលើថាពួកគេបានជួយគ្នាទៅវិញទៅមក ជាមួយនឹងសកម្មភាពប្រកបរបរចិញ្ចឹមជីវិត។ ដើម្បីបំពេញបន្ថែមប្រតិទិនរដូវកាល សកម្មភាពមួយចំនួន តូចនៃកំណត់ហេតុសកម្មភាពប្រចាំថ្ងៃ បានចងក្រងកំឡុងពេលសិក្សាស្រាវជ្រាវ បន្ថែមដោយការសង្កេត និងបំពេញបន្ថែមដោយទិន្នន័យស្រាវជ្រាវ។ ទោះបីជាមានភាពផ្សេងៗគ្នា នៅក្នុងការសកម្មភាពរកប្រាក់ ចំណូលដែលបង្កើតដោយស្ត្រីដែលបានផ្តល់បទសំភាសន៍ (រួមបញ្ចូលទាំង ការលក់កសិផល ការធ្វើ ពាណិជ្ជកម្មខ្នាតតូច ធ្វើការដាំដុះក្នុងដីផ្ទាល់ខ្លួន និងធ្វើការដោយលក់កំលាំងពលកម្ម) ស្ទើរទាំងអស់ ទទួលខុសត្រូវលើការរៀបចំអាហារសម្រាប់គ្រួសារ (សម្រាប់ការបរិភោគប្រចាំថ្ងៃ និងសម្រាប់រក្សាទុក សម្រាប់រយៈយូរ) ការសម្អាត ការបីបាច់ថែរក្សាកូន ថែទាំសួនដំណាំ ផ្តល់ចំណី និងទឹកដល់សត្វពាហនៈ និងការរកអុស។

ក្នុងភូមិ ដែលរដូវទឹកជំនន់មានផលប៉ះពាល់កើនឡើងខ្លាំង និងប៉ះពាល់ជាទូទៅទៅលើផ្ទះ និង ស្រែចំការ ការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ស្ត្រី អាចខុសគ្នាខ្លាំងទៅតាមរដូវកាល។ កំឡុងពេលទឹក ជំនន់ ក្មេងៗត្រូវបានបញ្ជូនទៅទីខ្ពស់មានសុវត្ថិភាព (នៅជាមួយសាច់ញាតិ ឬនៅវត្ត) ខណៈដែលស្ត្រីស្នា ក់នៅលំនៅផ្ទះបណ្តោះអាសន្ន ដើម្បីរៀបចំអាហារសម្រាប់ខ្លួនឯង និងប្តី ប្រមូល និងយកចំណីទៅឱ្យសត្វ ពាហនៈ (សត្វទាំងនោះទុកនៅទីខ្ពស់ ដែលបុរសបាននាំយក និងនៅចាំមើលសត្វពាហនៈទាំងនោះ) និង រកត្រីយកទៅលក់នៅផ្សារតាមទូក។ ក្នុងករណីព្រឹត្តិការគ្រោះទឹកជំនន់ធំៗ ដែលបានព្យាករណ៍ក្រោមការ ប្រែប្រួលអាកាសធាតុអាចនឹងមានរយៈពេលយូរ គ្រួសាររស់នៅបែកពីគ្នា និងស្ត្រីរស់នៅភូមិរងគ្រោះទឹក ជំនន់ ធ្វើការយ៉ាងពិបាក ក្នុងលក្ខខណ្ឌដ៏លំបាក និងប្រឈមមុខនឹងហានិភ័យខ្ពស់ ។

## ការដាក់បញ្ចូលគ្នាតាមផ្នែកនៃចំណេះដឹងប្រែប្រួលអាកាសធាតុរបស់សហគមន៍ និងទិន្នន័យវិទ្យាសាស្ត្រ




Figure 2: Recent variability in the onset, cessation and duration of the rainy season. Data were drawn from the PERSIANN-CDR dataset managed by NOAA, for a location near Kratie. The graph does not depict differences in the volume of rainfall between years, nor the availability of water.

ការវិភាគយ៉ាងសាមញ្ញទៅលើប្រវត្តិសាស្ត្រ ដែលត្រូវបានធ្វើដើម្បីកំណត់ថ្ងៃចាប់ផ្តើម រយៈពេល និងថ្ងៃបញ្ចប់នៃកំឡុងពេលមូសុងវស្សា ដោយប្រើទិន្នន័យមានស្រាប់សម្រាប់តំបន់គោលដៅសិក្សា។ រវាងឆ្នាំ១៩៨៣ ដល់ឆ្នាំ២០១៧ មធ្យមភាគថ្ងៃចាប់ផ្តើមនៃមូសុងវស្សាគឺថ្ងៃទី ៤ ខែមិថុនា និងមធ្យមភាគនៃថ្ងៃបញ្ចប់គឺថ្ងៃទី ២៩ ខែតុលា។ ដូចបានបង្ហាញក្នុងរូបទី ២ វាមានការប្រែប្រួលខ្លាំងក្នុងរយៈ ចាប់ផ្តើម និងបញ្ចប់នៃមូសុងវស្សាក្នុងឆ្នាំថ្មីៗនេះ តាមរយៈជាពិសេសថ្ងៃចាប់ផ្តើមយឺតបានកត់ត្រាទុកក្នុងឆ្នាំ២០១៧(ចុងខែកក្កដា) និងចាប់ផ្តើមលឿនក្នុងឆ្នាំ២០១៣ (ពាក់កណ្តាលខែមេសា)។

---

កំណើនការប្រែប្រួលនៃពេលចាប់ផ្តើម និងពេលបញ្ចប់នៃភ្លៀង បានកត់សម្គាល់ទុកដោយសហគមន៍មូលដ្ឋាន។ ក្នុងភូមិមួយ សមាជិកសហគមន៍បានលើកឡើងថា បើខ្យល់បក់ពីទិសខាងកើត នឹងមិនមានភ្លៀង ទៀតទេនៅរដូវវស្សានោះ ហើយបើគ្មានភ្លៀងសោះក្នុងខែតុលា ពួកគេព្យាករណ៍ថា នឹងមានគ្រោះរាំងស្ងួតនៅឆ្នាំក្រោយ។ ភាពកើតមានឡើង និងវិសាលភាពនៃទឹកជំនន់គឺមិនអាចការព្យាករណ៍ទុកបានពីមួយឆ្នាំទៅមួយឆ្នាំ សូម្បីតែនៅក្នុងឆ្នាំ។ នៅក្នុង ២០១៨ មានប្រកាសអាសន្នត្រឹមតែប៉ុន្មានថ្ងៃមុនទឹកជំនន់មកដល់ប៉ុណ្ណោះ កសិករខ្លះបានបាត់បង់ស្រូវវស្សារបស់ពួកគេ ទោះជានៅតំបន់ខ្ពស់ជាងគេក៏ដោយ។ មានចាស់ៗមួយចំនួន មានចំណេះដឹងមូលដ្ឋាន ទាក់ទងនឹងថាតើទឹកជំនន់ អាចមានទំហំតូច ឬធំ ផ្អែកលើការអានសញ្ញានៃបាតុភូតធម្មជាតិ ដូចជាកើនឡើងរុក្ខជាតិមួយចំនួន (ប៉ុន្តែចំណេះដឹងនេះគឺមិនមានប្រកពច្បាស់លាស់ទេ)។ កសិករ និងសហគមន៍ ដែលមានមធ្យោបាយធ្វើបែបនោះបាន គេបង្កើនការដាំដុះចម្រុះ និងផ្លាស់ប្តូរមុខដំណាំ ដើម្បីកាត់បន្ថយការពឹងផ្អែកតែលើរបបទឹកភ្លៀង។ ការងារជីកប្រឡាយ ឬស្រះទឹកដើម្បីរក្សាទឹកទុក (សម្រាប់ស្រោចស្រព ស្រះជ្រៅៗ និងលើកដីឲ្យខ្ពស់) ដាំដើមឈើ (សំខាន់ជាងគេដើមស្វាយ កៅស៊ូ និងចន្ទី) និងដាំដំណាំដែលធន់នឹរាំងស្ងួត និងអាចប្រផលក្នុងរយៈពេលខ្លី គឺជាយុទ្ធសាស្ត្របន្សាំដែលបានប្រើប្រាស់ដោយអ្នកភូមិ ។

## ការប្រើសប្រាស់សម្រាបគោលនយោបាយ

- សហគមន៍មូលដ្ឋាន និងការសន្និដ្ឋានវិទ្យាសាស្រ្ត យល់ស្របថាលំនាំទឹកភ្លៀង ទឹកជំនន់ និងភាពរាំងស្ងួតនៅតាមបណ្តោយដងទន្លេមេគង្គក្រោមក្នុងប្រទេសកម្ពុជា កាន់តែពិបាកព្យាករណ៍។ នេះបង្ហាញពីភាពសំខាន់សម្រាប់សហគមន៍នីមួយៗ ទាញយលប្រភពប្រាក់ចំនូលរបស់ពួកគេពីប្រព័ន្ធកសិកម្មដែលបានអភិវឌ្ឍជាមួយវដ្តទឹកជំនន់តាមរដូវនៃទន្លេមេគង្គ។
- នៅទីណាមានមធ្យោបាយដើម្បីធ្វើដូច្នេះ សហគមន៍នឹងអាចធ្វើកសិកម្មចំរុះ និងអនុវត្តការចិញ្ចឹមជីវិតដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ ពីការព្រួយបារម្ភពីគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ផ្សេងៗ។ តែមិនមែនការអនុវត្តទាំងអស់សុទ្ធតែទទួលបានជោគជ័យនោះទេ។ លើសពីនេះ នៅមានតម្លៃខ្ពស់ ក្នុងការផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ និងការលក់នៅទីផ្សារ។
- នៅក្នុងគោលនយោបាយ និងផែនការរបន្សាំ ចាំបាច់ត្រូវយកចិត្តទុកដាក់លើបទពិសោធន៍របស់អ្នករាល់គ្នានៅក្នុងសហគមន៍ ពិសេសក្រុមផ្សេងៗ ដែលអាចងាយនឹងទទួលរងគ្រោះកំឡុងពេលនៃទឹកជំនន់ និងគ្រោះរាំងស្ងួតផ្សេងៗ ដូចជាស្រ្តី មនុស្សចាស់ កុមារ ជនខ្វះទីជម្រក និងមនុស្សដែលមានមធ្យោបាយសេដ្ឋកិច្ចតិចតួច ។
- យោងតាមបទពិសោធន៍ និងចំណេះដឹងរបស់សហគមន៍ តាមរយៈដំណើរការចូលរួម បានបន្ថែមគុណតម្លៃទៅចំណេះដឹងដែលទទួលបានផ្នែកវិទ្យាសាស្រ្ត និងអាចផ្តល់ដំណឹងបានច្បាស់លាស់ សម្រាបការបង្កើតគោលនយោបាយ ដើម្បីអន្តរាគមន៍ពីក្រៅសហគមន៍ ពាក់ព័ន្ធនឹងវិធានការកាត់បន្ថយ និងការបន្សាំ។

## Source

This policy brief has been prepared by Dr Natasha Pauli and Ms Savuti Henningsen, The University of Western Australia, and is based on the following material:

Henningsen, S. (2019). Temporal and gendered dimensions of the impacts of environmental change along the lower Mekong River, Cambodia *(forthcoming)*. (Masters Research Thesis, University of Western Australia, Perth, Australia)

Edited by Professor Andreas Neef, The University of Auckland, New Zealand

About this publication: This policy brief has been developed for the APN project “Climate Change Adaptation in Post-Disaster Recovery Processes: Flood-Affected Communities in Cambodia and Fiji” (CAF2016-RR05-CMY-Neef) under APN’s Climate Adaptation Framework. For full details of this project, including news and events, project activities, publications and presentations, please visit the project website at http://www.climatechangeplus.net.

March 2019